00866002

E236/2/Corr-1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សំណើសុំការកែតម្រូវ

**សំណុំរឿងលេខ៖** 002/19-09-2007-ECCC/TC

| កែលើឯកសារលេខ៖ | ERN(s): | កាលបរិច្ឆេទ៖ | ប្រភេទកំណែ៖ |
|---|---|---|---|
| E236/2 | 00865068 | 3 Dec 2012 | ☒ កែលើឯកសារដើម<br>☐ កែលើឯកសារបកប្រែ<br>☐ រៀបចំទាត់ថ្នាក់ឡើងវិញ |

| មូលហេតុនៃការកែតម្រូវ៖ |
|---|
| ខុសឈ្មោះរហស្សនាមរបស់សាក្សី |

| សេចក្តីលម្អិតនៃការកែតម្រូវ៖ |
|---|
| សូមមើលឯកសារភ្ជាប់ |

ភាគីស្នើសុំ៖ អង្គជំនុំជម្រះសាលាដំបូង — ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ — ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ — ហត្ថលេខា៖

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / 12 / 2012
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២

**ជូនចំពោះ:** **ភាគីនៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន, ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង, និង អង្គភាពគាំពារសាក្សី និងអ្នកជំនាញ**

**កម្មវត្ថុ:** **ការប្រកាសអំពីសាក្សីដែលគ្រោងផ្តល់សក្ខីកម្មនាពេលខាងមុខ**

បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាជនជាប់ចោទ អៀង សារី មានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ និងបានបង្គាប់ឱ្យគាត់ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតាមមធ្យោបាយសោតទស្សន៍ (ឯកសារ E238/9) នោះ នៅពេលនេះ អង្គជំនុំជម្រះសូមជូនដំណឹងទៅភាគីអំពីសាក្សីទាំងឡាយដែលគ្រោងនឹងផ្តល់សក្ខីកម្មក្នុងសវនាការ នាខែ ធ្នូ និងសវនាការនៅពេលក្រោយៗទៀត។

បន្ទាប់ពីស្តាប់សក្ខីកម្មសាក្សីទាំងឡាយដែលត្រូវបានកំណត់កាលបរិច្ឆេទរួចរាល់ដើម្បីផ្តល់សក្ខីកម្មដែលភាគីបានទទួលការជូនដំណឹងរួចហើយ អង្គជំនុំជម្រះនឹងចាប់ផ្តើមបន្តនូវការស្តាប់សក្ខីកម្មរបស់សាក្សីពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ (ឯកសារ E172/29) ដោយចាប់ផ្តើមពីសាក្សីដែលមានរហស្សនាម TCW-307~~695~~ និងបន្ទាប់មកទៀតគឺសាក្សីដែលមានរហស្សនាម TCW-695~~398~~។ បន្ថែមពីលើសាក្សីទាំងឡាយដែលត្រូវបានកំណត់កាលបរិច្ឆេទកាលពី-ពេលមុនដើម្បីផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា (ឯកសារ E233) អង្គជំនុំជម្រះ

នឹងកោះហៅសាក្សីដែលមានរហស្សនាម TCW-425 (ឯកសារ E172) នៅពេលសមស្របខាងមុខ។ លោក Stephen Heder ក៏នឹងត្រូវកោះហៅឱ្យចូលខ្លួនមកផ្តល់សក្ខីកម្មផងដែរ ដោយពិនិត្យទៅលើឯកសារជាច្រើននៅក្នុងសំណុំរឿង និងឯកសារដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដែល-គាត់បានដឹងផ្ទាល់ និង/ឬ គាត់ជាអ្នកនិពន្ធ។

ជាងនេះទៀត អង្គជំនុំជម្រះសាលាដំបូងឯកភាពតាមសំណើរបស់សហព្រះរាជអាជ្ញា (ឯកសារ E236/1/2) ដែលស្នើសុំស្តាប់សក្ខីកម្មរបស់សាក្សីដែលមានរហស្សនាម TCW-161 និង TCW-565 ដោយហេតុថាពួកគាត់ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ហើយការស្តាប់សក្ខីកម្មរបស់ពួកគាត់អាចនាំទៅដល់ការបញ្ជាក់ការពិត។ អង្គជំនុំជម្រះស្នើសុំឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញទាក់ទងទៅសាក្សីទាំងនេះ និងជូនដំណឹងមកអង្គជំនុំជម្រះអំពីលទ្ធភាពដែលពួកគាត់អាចផ្តល់សក្ខីកម្មបាន។

មេធាវីការពារក្តីបានស្នើសុំស្តាប់សក្ខីកម្មរបស់សាក្សី និងអ្នកជំនាញមួយចំនួន (ឯកសារE236)។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាសំណើទាំងនេះ និងឯកភាពតាមសំណើរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន និង នួន ជា ដែលស្នើសុំកោះហៅសាក្សីដែលមានរហស្សនាម TCW-126 និងសាក្សីដែលមានរហស្សនាម TCW-570។ អង្គជំនុំជម្រះនឹងកំណត់កាលបរិច្ឆេទនៃការផ្តល់សក្ខីកម្មរបស់ពួកគាត់នៅពេលសមស្របខាងមុខ។ សេចក្តីសម្រេចនានាពាក់ព័ន្ធនឹងបុគ្គលផ្សេងទៀតដែលភាគីបានស្នើសុំស្តាប់សក្ខីកម្ម និងបុគ្គលដូចដែលបានបង្ហាញរហស្សនាមក្នុងឯកសារ E236 នឹងចេញក្នុងពេលសមស្របខាងមុខ។

ជាចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចពុំស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-35 ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន ដោយហេតុថាអង្គជំនុំ-ជម្រះធ្លាប់បានសម្រេចរួចហើយថាសក្ខីកម្មនេះជារួមគឺច្រំដែលជាមួយភស្តុតាងផ្សេងៗ ដែលបានផ្តល់រួច ឬគ្រោងនឹងផ្តល់នៅចំពោះមុខអង្គជំនុំជម្រះក្នុងពេលឆាប់ៗខាងមុខ។ ប៉ុន្តែភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំកោះហៅដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-35 ក្នុងអំឡុងពេលដែលបានលៃលកទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញភស្តុតាងអំពីទុក្ខវេទនារបស់ពួកគាត់បាន (ឯកសារ E218 កថាខណ្ឌ ១៨)។